**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០២.២៣១/០៧ គជប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

## សន្លឹកឆ្នោតចំនួន ៧ ខេត្ត ត្រូវបាន គ.ជ.ប ដឹកជញ្ជូនពីរោងពុម្ព ទៅកាន់ឃ្លាំង គ.ជ.ប

នៅព្រឹកថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ គ.ជ.ប បានធ្វើការដឹកជញ្ជូនសន្លឹកឆ្នោត ដែលបានវេចខ្ចប់រួចចំនួន ៧ ខេត្ត ចេញពីរោងពុម្ពដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ៩ ផ្លូវ ៣៤៥ សង្កាត់ បឹងកក់ទី ១ ខណ្ឌ ទួលគោក រាជធានី ភ្នំពេញ ទៅកាន់ឃ្លាំង គ.ជ.ប ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៥ សង្កាត់ គីឡូម៉ែត្រលេខ ៦ ខណ្ឌ ឫស្សីកែវ រាជធានី ភ្នំពេញ (ក្នុងមជ្ឈមណ្ឌលឃ្លាំងពាណិជ្ជកម្មគីឡូម៉ែត្រលេខ ៦) ។

ការដឹកជញ្ជូននេះ ត្រូវបានអញ្ជើញចូលរួមឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ពីតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មានមួយចំនួន ។

លោក **ហ៊ី រ៉ុង** ប្រធាននាយកដ្ឋានប្រតិបត្តិការ គ.ជ.ប បានមានប្រសាសន៍ថា សន្លឹកឆ្នោតចំនួន ៧ ខេត្ត នេះ រួមមាន ៖

១- ខេត្ត កំពង់ឆ្នាំង មាន ចំនួន **៦៩** កេស ស្មើនឹង **៩២២** កញ្ចប់ គិតជាសន្លឹកមាន ចំនួន **៣០៧.៧៥០** សន្លឹក

២- ខេត្ត កំពង់ស្ពឺ មាន ចំនួន **៨៧** កេស ស្មើនឹង **៧៨០** កញ្ចប់ គិតជាសន្លឹកមាន ចំនួន **៤៧១.៣០០** សន្លឹក

៣- ខេត្ត កំពង់ធំ មាន ចំនួន **៨១** កេស ស្មើនឹង **៧១៣** កញ្ចប់ គិតជាសន្លឹកមានចំនួន **៤១៥.០០០** សន្លឹក

៤- ខេត្ត កោះកុង មាន ចំនួន **៣៣** កេស ស្មើនឹង **១៦៨** កញ្ចប់ គិតជាសន្លឹកមាន ចំនួន **៩៥.៩៥០** សន្លឹក

៥- ខេត្ត ពោធិ៍សាត់ មាន ចំនួន **៤៩** កេស ស្មើនឹង **៤៣៦** កញ្ចប់ គិតជាសន្លឹកមាន ចំនួន **២៥៥.៨៥០** សន្លឹក

៦- ខេត្ត ឧត្តរមានជ័យ មាន ចំនួន **២៤** កេស ស្មើនឹង **១៦៩** កញ្ចប់ គិតជាសន្លឹកមាន ចំនួន **៩៦.៨៥០** សន្លឹក

៧- ខេត្ត កំពត មាន ចំនួន **៩២** កេស ស្មើនឹង **៦១១** កញ្ចប់ គិតជាសន្លឹកមាន ចំនួន **៣៨៩.១៥០** សន្លឹក

លោក ហ៊ី រ៉ុង ក៏បានបញ្ជាក់បន្ថែមទៀតថា សន្លឹកឆ្នោតដែលបានបោះពុម្ពរួច និងកំពុងធ្វើការវេចខ្ចប់មានចំនួន ៨ ខេត្តទៀត គឺសន្លឹកឆ្នោតខេត្តកណ្តាល ក្រចេះ មណ្ឌលគីរី ព្រៃវែង រតនគីរី សៀមរាប ស្វាយរៀង និងក្រុងព្រះសីហនុ ហើយសន្លឹកឆ្នោតដែលកំពុងធ្វើការបោះពុម្ព គឺសន្លឹកឆ្នោតសម្រាប់ខេត្ត កំពង់ចាម ។

សូមបញ្ជាក់ថា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ គ.ជ.ប ត្រូវផលិតសន្លឹកឆ្នោតចំនួន **៨.៨៤១.៩៥០** សន្លឹក សម្រាប់អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការឆ្នាំ ២០០៦ ចំនួន **៧.៧៩៩.៣៧១** នាក់ ។ សន្លឹកឆ្នោតដែលលើស គឺជាសន្លឹកឆ្នោតត្រៀមបំរុងសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដែលមានចំនួនពី **៥០** ទៅ **៩៩** សន្លឹក ។ សន្លឹកឆ្នោតទាំងនេះ នឹងត្រៀមដឹកចេញពីឃ្លាំង គ.ជ.ប ទៅគ្រប់ គខ/កប ចាប់ពីថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៧ តទៅ ។